**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប**
**ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)**
**លេខាធិការដ្ឋាន**

លេខៈ ០០១ សរ.លា.ន / គ.ជ.អ.ប

ថ្ងៃច័ន្ទ ៥រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០២០

**គោរពជូន**

**ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**

**<u>កម្មវត្ថុ</u>** ÷ សេចក្តីណែនាំក្នុងការរៀបចំបញ្ជីឈ្មោះអ្នកទទួលការលទ្ធកម្មគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០២១។

**<u>យោង</u>** ÷ សេចក្តីសម្រេចលេខ ០៩៧ សសរ/គ.ជ.អ.ប ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបថា៖ សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧ (PIM) តម្រូវឱ្យរាជធានី ខេត្តរៀបចំបញ្ជីឈ្មោះអ្នកទទួលការប្រចាំឆ្នាំបានចប់សព្វគ្រប់មិនឱ្យហួសពីថ្ងៃទី ៣១ ខែធ្នូ។ ដំណើរការនេះ ត្រូវចាប់ផ្តើមពីការបង្កើតគណៈកម្មការបុរេលក្ខណៈសម្បត្តិអ្នកទទួលការ និងការប្រកាសស្តីពីការដាក់ពាក្យចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០២១ តាមរាជធានី ខេត្តនីមួយៗ តាមទម្រង់ទី២៥.២ ដែលការប្រកាសនេះមិនត្រូវឱ្យយឺតជាងថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០២០ ឡើយ និងត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ ជាពិសេសត្រូវបិទផ្សព្វផ្សាយលើក្តារព័ត៌មានរបស់សាលារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ។ ដោយសារមានភាពមិនប្រក្រតីក្នុងការរៀបចំបញ្ជីឈ្មោះអ្នកទទួលការក្នុងខេត្តមួយចំនួនកន្លងមក លេខាធិការដ្ឋាន គ.ជ.អ.ប ស្នើសុំគណៈកម្មការបុរេលក្ខណៈសម្បត្តិរាជធានី ខេត្តយកចិត្តទុកដាក់ និងពង្រឹងនីតិវិធីរៀបចំបញ្ជីឈ្មោះអ្នកទទួលការចាប់ពីការទទួលពាក្យស្នើសុំ ក៏ដូចជាការវាយតម្លៃគុណភាពគម្រោង គ្រឿងចក្រ និងបុគ្គលិកដល់ទីកន្លែង ដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងការប្រកួតប្រជែង។ ដំណើរការ និងនីតិវិធីនៃការរៀបចំបញ្ជីឈ្មោះអ្នកទទួលការមានចែងលម្អិតក្នុងជំពូក ៣ ចំណុច ៣.២ នៃសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧ (PIM)។

អាស្រ័យដូចបានជម្រាបជូន សូម **ឯកឧត្តម លោកជំទាវ** ចាត់វិធានការតាមខ្លឹមសារនៃសេចក្តីណែនាំនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

សូម **ឯកឧត្តម លោកជំទាវ** ទទួលនូវការគោរពរាប់អានដ៏ស្មោះអំពីខ្ញុំ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

ង៉ាន់ ពិទៀ

មហាវិថីព្រះនរោត្តមៈ លេខាធិការដ្ឋាននៃ គ.ជ.អ.ប ក្រសួងមហាផ្ទៃ។ ទូរស័ព្ទៈ (៨៥៥-២៣) ៧២០ ០៦១ / ៧២០ ០៣៨ E-mail: info@ncdd.gov.kh Website: www.ncdd.gov.kh